**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ០០៤ /២១. សណន

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងវិធានការសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយតាមបណ្តាគោលដៅចត្តាឡីស័កទាំងអស់ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ

**ដើម្បីរក្សាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយតាមបណ្តាគោលដៅចត្តាឡីស័កទាំងអស់ក្នុងមូលដ្ឋានរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញ សូមដាក់ចេញនូវសេចក្តីណែនាំ ដូចខាងក្រោម៖**

១. គ្រប់គោលដៅចត្តាឡីស័ក រួមទាំង លំនៅដ្ឋានឯកជន អគារស្នាក់នៅរួម-ខុនដូ ក្លឹបកំសាន្ត និងទីតាំងអាជីវកម្មដែលជាប់ពាក់ព័ន្ធក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០-កុម្ភៈ"** និងត្រូវបានកំណត់ថាជាទីតាំងចត្តាឡីស័កទាំងអស់ គឺស្ថិតក្រោមការគ្រប់គ្រងរបស់**គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ**។

២. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ប្រគល់ភារកិច្ចជូនរដ្ឋបាលខណ្ឌទាំង១៤ លើការងារការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយតាមបណ្តាគោលដៅចត្តាឡីស័កក្នុងដែនសមត្ថកិច្ច ដោយត្រូវបង្កើតក្រុមការងារគ្រប់គ្រងទីតាំងចត្តាឡីស័កជាក់លាក់ទៅតាមគោលដៅ ឬ តំបន់ប្រមូលផ្តុំ អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រ និងទំហំប្រតិបត្តិការ ក្នុងនោះ ក្រុមការងារនីមួយៗត្រូវមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន កងកម្លាំងប្រដាប់អាវុធ ក្រុមគ្រូពេទ្យប្រចាំការ ម្ចាស់ទីតាំង (ករណីទីតាំងឯកជន) និងភាគីពាក់ព័ន្ធមួយចំនួនទៀតអាស្រ័យលើតម្រូវការចាំបាច់។

៣. ក្រុមការងារគ្រប់គ្រងទីតាំងចត្តាឡីស័ក មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ដាក់កម្លាំងប្រចាំការ **២៤ម៉ោង/២៤ម៉ោង** ដោយអាចបែងចែកវេនយាមជា **២ ឬ ៣ វេន**
- ទទួលខុសត្រូវទាំងស្រុងលើការងារការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយជុំវិញបរិវេណគោលដៅចត្តាឡីស័កដែលខ្លួនគ្រប់គ្រង
- ហ៊ុមព័ទ្ធទីតាំង និង/ឬ រៀបចំច្រកទ្វារចេញ-ចូលសម្រាប់ធានាការគ្រប់គ្រង និងត្រួតពិនិត្យមិនឱ្យមានការចេញ-ចូលដោយសេរី។ រាល់ការចេញ-ចូល ដាច់ខាតត្រូវមានការត្រួតពិនិត្យពីមន្ត្រីសុខាភិបាល និងការអនុញ្ញាតជាមុនពីក្រុមការងារគ្រប់គ្រងទីតាំងចត្តាឡីស័ក ដែលកំពុងឈរជើងនៅទីតាំងនោះ
- គ្រប់គ្រង ឃ្លាំមើល ណែនាំ និងមានចំណាត់ការឱ្យបានទាន់ពេលវេលា ដើម្បីធានាថាក្រុមបុគ្គលទាំងឡាយ ដែលកំពុងធ្វើចត្តាឡីស័កស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ពិតជាបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមវិធានចត្តាឡីស័ក និងការណែនាំរបស់ក្រសួងសុខាភិបាល



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៥ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ភ្ជាប់ជាប់នូវតម្រូវការចាំបាច់របស់អ្នកធ្វើចត្តាឡីស័ក ក្នុងទីតាំងដែលខ្លួនគ្រប់គ្រង ដើម្បីដោះស្រាយជូនពួកគាត់។ ក្នុងករណីមិនអាចដោះស្រាយបាន ត្រូវរាយការណ៍ និងសុំយោបល់ដឹកនាំពីគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌសាមី ឬ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ
- កត់ត្រាអត្តសញ្ញាណ (ឈ្មោះ, លេខទូរស័ព្ទ និងអាសយដ្ឋាន) របស់បុគ្គលដែលបានយកកញ្ចប់អាហារ ឬ សម្ភារៈផ្សេងៗ ជូនដល់អ្នកដែលកំពុងធ្វើចត្តាឡីស័ក ក្នុងនោះ ក្រុមការងារត្រូវបាញ់អាល់កុលសម្លាប់មេរោគ និងត្រួតពិនិត្យរាល់កញ្ចប់អាហារ និងសម្ភារៈទាំងនោះ ឱ្យបានច្បាស់លាស់ មុននឹងប្រគល់ជូនទៅផ្នែកខាងក្នុង។ ប្រសិនបើមានការសង្ស័យ ត្រូវឃាត់ខ្លួនបុគ្គលនោះ រួចរាយការណ៍ជាបន្ទាន់ទៅគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌសាមី
- រៀបចំផែនការសន្តិសុខត្រៀមបង្ការទុកជាមុន សម្រាប់ទប់ទល់រាល់ព្រឹត្តិការណ៍ ឬ ការបង្កចលាចលនានា ដែលអាចកើតមានជាយថាហេតុ ក្នុងគោលដៅចត្តាឡីស័កដែលខ្លួនគ្រប់គ្រង។

៤. ចំពោះពេលវេលាដែលអាចអនុញ្ញាតឱ្យនាំចូលនូវកញ្ចប់អាហារ ឬ សម្ភារៈផ្សេងៗ ជូនដល់អ្នកដែលកំពុងធ្វើចត្តាឡីស័ក ត្រូវបានកំណត់ទៅតាមរបបអាហារ **៣ (បី) ពេល ក្នុងមួយថ្ងៃ** រួមមាន៖
   - **ពេលព្រឹក ៖ ម៉ោង ០៦:០០ នាទី ដល់ ម៉ោង ០៧:០០ នាទី**
   - **ពេលថ្ងៃត្រង់ ៖ ម៉ោង ១១:០០ នាទី ដល់ ម៉ោង ១២:០០ នាទី**
   - **ពេលល្ងាច ៖ ម៉ោង ១៧:០០ នាទី ដល់ ម៉ោង ១៨:០០ នាទី ។**

៥. គ្រប់គោលដៅចត្តាឡីស័កទាំងអស់ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមការណែនាំរបស់ក្រសួងសុខាភិបាល និងវិធានការ "**៣ ការពារ និង ៣ កុំ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, អនុក្រឹត្យស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, ប្រកាស និងសេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ប្រធានមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ក្រុមការងារគ្រប់គ្រងទីតាំងចត្តាឡីស័ក និងម្ចាស់ទីតាំងចត្តាឡីស័កឯកជន ព្រមទាំងក្រុមបុគ្គលដែលកំពុងធ្វើចត្តាឡីស័កទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យទទួលបានលទ្ធផលល្អ និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ១១កើតខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
-រដ្ឋបាលខណ្ឌទាំង១៤
-មន្ទីរ-អង្គភាពពាក់ព័ន្ធ
-គ្រប់គោលដៅចត្តាឡីស័ក
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh